00864693 E189/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 23 / 11 / 2012
ម៉ោង (Time/Heure) : 08:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម និល ណុន ប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម យ៉ា សុខន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម យូ អុត្តារា |
| កាលបរិច្ឆេទ: | ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# សេចក្តីសម្រេចលើសំណើសុំឲ្យមានវិធានការជាបន្ទាន់ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង (ឯកសារ E189)

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ជនជាប់ចោទ**
នួន ជា
អៀង សារី
ខៀវ សំផន

**មេធាវីជនជាប់ចោទ**
សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
គង់ សំអុន
Arthur VERCKEN
Jacques VERGÈS
Anta GUISSE

00864694

E189/3

## ១. សេចក្តីផ្តើម

១. កាលពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ មេធាវីអន្តរជាតិរបស់ជនជាប់ចោទ នួន ជា បានដាក់សំណើមួយមកអង្គជំនុំជម្រះសាលាដំបូងសុំឱ្យមានវិធានការជាបន្ទាន់ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង។ សហព្រះរាជអាជ្ញាបានដាក់សារណាតបទៅនឹងសំណើសុំនេះកាលពីថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១២[1]។ នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១២ មេធាវីអន្តរជាតិការពារជនជាប់ចោទ នួន ជា បានដាក់សំណើសុំឱ្យមានវិធានការបន្ទាន់ដោយអនុលោមតាមវិធាន ៣៥ មួយបន្ថែមទៀត ទាក់ទងនឹងសេចក្តីថ្លែងការណ៍របស់លោក ហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេសរបស់កម្ពុជា[2]។

២. កាលពីថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") បានចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ដែលបានប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានចេញដោយអនុលោមតាម វិធាន៣៥ ពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន។ អង្គជំនុំជម្រះតុលាការកំពូលបានបកស្រាយអំពីវិសាលភាពនៃវិធានផ្ទៃក្នុងនេះ[3]។ នៅថ្ងៃនេះ អង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចដាច់ដោយឡែក ទាក់ទងនឹងសំណើទាំង ២ ខាងលើរបស់មេធាវីអន្តរជាតិការពារជនជាប់ចោទ នួន ជា ដោយអនុលោមតាមវិធាន ៣៥ ដែលសំណើទាំងនេះ អង្គជំនុំជម្រះពុំទាន់បានចេញសេចក្តីសម្រេចនៅឡើយ[4]។

## ២. សារណា

៣. សមាជិកអន្តរជាតិនៃមេធាវីការពារជនជាប់ចោទ នួន ជា លើកឡើងថាការលាលែងរបស់ចៅក្រម Laurent KASPER-ANSERMET ពីមុខតំណែងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង សបញ្ជាក់ថាមន្ត្រីកម្ពុជានៅ អ.វ.ត.ក បានទទួលរងឥទ្ធិពលពីរដ្ឋាភិបាល និងពុំមានសមត្ថភាព

---

[1] សំណើសុំឱ្យមានវិធានការជាបន្ទាន់ដោយអង្គជំនុំជម្រះដោយអនុលោមតាមវិធាន ៣៥, ឯកសារ E189, ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ ("សំណើសុំរបស់ នួន ជា")។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា ដែលស្នើសុំឱ្យចាត់វិធានការជាបន្ទាន់ ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង, ឯកសារ E189/1, ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១២ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា")។

[2] សំណើអនុលោមតាមវិធាន ៣៥ សុំឱ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹងរដ្ឋមន្ត្រីការបរទេស ហោ ណាំហុង, ឯកសារ E219, ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១២។

[3] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង, ឯកសារ E176/2/1/4, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក ដោយអនុលោមតាមវិធាន ៣៥")។

[4] *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើអនុលោមតាមវិធាន ៣៥ សុំឱ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹងរដ្ឋមន្ត្រីការបរទេស ហោ ណាំហុង, ឯកសារ E219/3 ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២។

ដើម្បីបំពេញតួនាទីប្រកបដោយឯករាជ្យបានឡើយ[5]។ ដើម្បីគាំទ្រអំណះអំណាងរបស់ខ្លួនដែលថា អ.វ.ត.ក ពុំមាន "ឯករាជ្យភាពគ្រប់គ្រាន់" ពីរាជរដ្ឋាភិបាលកម្ពុជានោះមេធាវីអន្តរជាតិទាំងនោះ បានលើកយករបាយការណ៍របស់អ្នកឃ្លាំមើលតុលាការ និងសេចក្តីអត្ថាធិប្បាយតាមបណ្តាញ ផ្សព្វផ្សាយព័ត៌មាន ពាក់ព័ន្ធនឹងការលាលែងរបស់ចៅក្រម KASPER-ANSERMET ពីភារកិច្ច របស់គាត់ក្នុងសំណុំ រឿង ០០៣ និង ០០៤[6]។

៤. សមាជិកអន្តរជាតិនៃក្រុមមេធាវីការពារក្តី នួន ជា លើកឡើងថាសុចរិតភាពនៃឯកសារសំណុំរឿង ០០២ "មានភាពគួរឱ្យមន្ទិលខ្លាំង" ដោយបានចោទប្រកាន់ថាសាក្សីសំខាន់ៗមួយចំនួន ពុំត្រូវបាន ស្តាប់យកចម្លើយក្នុងអំឡុងដំណាក់កាលមុនអង្គសេចក្តី ហើយការចាកចេញរបស់ចៅក្រម Siegfried BLUNK និងចៅក្រម KASPER- ANSERMET ដែលមានកាតព្វកិច្ចស៊ើបសួរលើ សំណុំរឿង ០០៣ និង ០០៤ "ត្រូវបានគេមើលឃើញថា បង្ហាញឱ្យឃើញនូវភាពគ្មានទំនុកចិត្តលើ សហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង ដែលជាបុគ្គលម្នាក់ទទួលខុសត្រូវយ៉ាងសំខាន់ក្នុងការ រៀបចំកិច្ចការស៊ើបសួរក្នុងសំណុំរឿង ០០២"[7]។ សមាជិកអន្តរជាតិនៃក្រុមមេធាវីការពារក្តី នួន ជា បានអះអាងទៀតថាលទ្ធផលនៃសំណុំរឿង ០០២ គឺត្រូវបានកំណត់ទុកជាមុន ហើយសេចក្តី ថ្លែងការណ៍ជាសាធារណៈរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ស្តីពីពិរុទ្ធភាពរបស់ជនជាប់ចោទនឹង រារាំងមិនឱ្យចៅក្រមកម្ពុជានៃអង្គជំនុំជម្រះសាលាដំបូង ចេញសាលក្រមមួយប្រកបដោយឯករាជ្យ បានទេ[8]។ យោងតាមមេធាវីអន្តរជាតិរបស់ នួន ជា ការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង ០០៣ និង ០០៤ លេចចេញយ៉ាងច្បាស់ក្រឡែត បើទោះ បីជា "វិធីសាស្ត្រដ៏ប៉ិនប្រសព្វត្រូវបានប្រើប្រាស់ដោយបុគ្គលដដែល ដើម្បីធានាឱ្យមានការផ្តន្ទា ទោសក្នុងសំណុំរឿង ០០២ និងដើម្បីបិទបាំងភាពអាម៉ាស់របស់មន្ត្រីរដ្ឋាភិបាលកម្ពុជា និង/ឬការ លាតត្រដាងការពិតណាមួយដែលអាចកើតមាន"[9]។ មេធាវីអន្តរជាតិបានស្នើសុំឱ្យអង្គជំនុំជម្រះ សាលាដំបូងបដិសេធយុត្តាធិការរបស់ខ្លួន ហើយស្នើសុំឱ្យចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះសាលា ដំបូងលាឈប់ពីតំណែងនៅ អ.វ.ត.ក ឬសម្រេចឱ្យ នួន ជា រួចផុតពីការចោទប្រកាន់ ដោយ សំអាងថាការជំនុំជម្រះមួយប្រកបដោយយុត្តិធម៌ពុំអាចធ្វើទៅបាន[10]។ សមាជិកអន្តរជាតិនៃក្រុម មេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យមានការទទួលស្គាល់អំពីផលប៉ះពាល់ជាព្យសនកម្មនៃលិខិត

[5] សំណើរបស់ នួន ជា, កថាខណ្ឌ ១៩។

[6] សំណើរបស់ នួន ជា, កថាខណ្ឌ ២០។

[7] សំណើរបស់ នួន ជា, កថាខណ្ឌ ២៣ក។

[8] សំណើរបស់ នួន ជា, កថាខណ្ឌ ២៣ខ។

[9] សំណើរបស់ នួន ជា, កថាខណ្ឌ ២៤ (ដោយបានលើកឡើងអំពីការបដិសេធរបស់ចៅក្រម យូ ប៊ុនឡេង ពុំព្រមចុះហត្ថលេខា លើដីកាកោះហៅសាក្សីដែលជាមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា)។

[10] សំណើរបស់ នួន ជា, កថាខណ្ឌ ២៦។

លាលែងពីមុខតំណែងរបស់ចៅក្រម KASPER-ANSERMET និងការស៊ើបអង្កេតពេញលេញអំពីផលប៉ះពាល់នៃការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលកម្ពុជាទៅលើភាពត្រឹមត្រូវនៃសំណុំរឿង ០០២ និងការផ្អាកកិច្ចដំណើរការនីតិវិធីដោយរង់ចាំលទ្ធផលនៃកិច្ចស៊ើបអង្កេតនេះសិន[11]។ ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងទាំងមូលបដិសេធសំណើនេះ មេធាវីអន្តរជាតិស្នើសុំឱ្យចៅក្រម CARTWRIGHT និងចៅក្រម LAVERGNE ចេញមតិដាច់ដោយឡែកមួយដើម្បីថ្កោលទោសការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលកម្ពុជា[12]។

៥. ជាការឆ្លើយតប សហព្រះរាជអាជ្ញាលើកឡើងថាសំណើរបស់មេធាវីអន្តរជាតិរបស់ នួន ជា ដែលស្នើសុំឱ្យមានកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៣៥ និងការផ្អាកនីតិវិធីក្នុងសំណុំរឿង ០០២ គួរត្រូវបានបដិសេធ។ សំណើសុំខាងលើពុំបានបង្ហាញឱ្យឃើញអំពីការរំលោភណាមួយលើសិទ្ធិរបស់ជនជាប់ចោទក្នុងការជំនុំជម្រះដែលកំពុងប្រព្រឹត្តទៅក្នុងសំណុំរឿង ០០២ ឡើយ ហើយជំនួសមកវិញ សំណើសុំរបស់មេធាវីអន្តរជាតិការពារ នួន ជា ធ្វើឡើងផ្អែកតាមសេចក្ដីសន្និដ្ឋានដែលពុំមានមូលដ្ឋានច្បាស់លាស់ដែលមានប្រភពចេញមកពីសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ទៅវិញ។ ជាងនេះទៀត សំណើសុំខាងលើជាសំណើចំដែលត្រួតលើសំណើមុនៗដែលត្រូវបានបដិសេធទាំងនៅអង្គជំនុំជម្រះសាលាដំបូង និងទាំងនៅអង្គជំនុំជម្រះតុលាការកំពូល។ ជា ជាងការចង្អុលបង្ហាញអំពីទង្វើជាក់លាក់ ឬបញ្ហាជាក់ស្ដែងក្នុងសំណុំរឿង ០០២ ដែលគួរត្រូវបានស៊ើបអង្កេតដោយអនុលោមតាមវិធាន ៣៥ នោះ ជំនួសមកវិញ សំណើនេះបានសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបើកកិច្ចស៊ើបសួរជាទូទៅដោយគ្មានដែនកំណត់អំពីផលប៉ះពាល់ទៅលើភាពយុត្តិធម៌នៃសំណុំរឿង ០០២ ដោយសារការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលកម្ពុជាដែលត្រូវបានចោទប្រកាន់[13]។

៦. បញ្ហាជាក់លាក់តែមួយគត់ដែលមេធាវីអន្តរជាតិរបស់ជនជាប់ចោទ នួន ជា បានលើកឡើង គឺការស្នើសុំស្ដាប់សក្ខីកម្មរបស់សម្ដេចវររាជបិតា នរោត្ដម សីហនុ និងមន្ត្រីរាជរដ្ឋាភិបាលកម្ពុជាចំនួន ០៦ រូប៖ ដែលបញ្ហាទាំងនេះជាបញ្ហាស្ថិតនៅចំពោះមុខអង្គជំនុំជម្រះ និងស្ថិតក្រោមឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការសម្រេចថាតើត្រូវបន្តនីតិវិធីដូចម្ដេចពាក់ព័ន្ធនឹងបុគ្គលដែលអាចធ្វើជាសាក្សី[14]។ ដោយហេតុថាមេធាវីការពារក្ដីឱ្យជនជាប់ចោទ នួន ជា បានជំទាស់ទៅ

---

[11] សំណើរបស់ នួន ជា, កថាខណ្ឌ ២៨។

[12] សំណើរបស់ នួន ជា, កថាខណ្ឌ ២៨។

[13] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១, កថាខណ្ឌ ៤, កថាខណ្ឌ ៩-១០។

[14] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៤ (សម្រង់ត្រូវបានលុបចោល)។

និងសេចក្តីថ្លែងរបស់បុគ្គលទាំងនេះ ដែលត្រូវបានបង្ហាញជាភស្តុតាង ទើបភាពពាក់ព័ន្ធ ឬសារៈសំខាន់នៃសក្ខីកម្មរបស់ពួកគាត់កំពុងស្ថិតក្នុងការពិចារណារបស់អង្គជំនុំជម្រះ[15]។

៧. ជាងនេះទៀត សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដោយសម្លេងជាឯកច្ឆន្ទមួយចំនួន សបញ្ជាក់អំពីឯករាជ្យភាពនៃអង្គជំនុំជម្រះសាលាដំបូង និងបានកាត់បន្ថយតម្លៃនៃការអះអាងរបស់មេធាវីអន្តរជាតិការពារក្តី នួន ជា ដែលថាការផ្តន្ទាទោសជនជាប់ចោទទាំងអស់គឺបានកំណត់ទុកជាមុន ឬមានការជ្រៀតជ្រែកខាងនយោបាយដែលត្រូវបានចោទប្រកាន់ និងរារាំងមិនឲ្យអង្គជំនុំជម្រះធ្វើការកាត់សេចក្តីជនជាប់ចោទដោយយុត្តិធម៌ក្នុងសំណុំរឿង០០២[16]។ ជាចុងក្រោយ សហព្រះរាជអាជ្ញាបានអះអាងថាសំណើរបស់ នួន ជា ពុំបានបំពេញតាមលក្ខខណ្ឌអតិបរមាដែលចាំបាច់សម្រាប់ការ បញ្ចប់កិច្ចដំណើរការនីតិវិធីដែលជាសំណងទៅនឹងការរំលោភបំពានសិទ្ធិរបស់ជនជាប់ចោទឡើយ។ ផ្ទុយពីការលើកឡើងនេះ សិទ្ធិរបស់ជនជាប់ចោទ និងភាគីដទៃ ត្រូវបានគាំពារប្រសើរបំផុតនៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះដែលកំពុងតែបន្តនេះ ដោយអង្គជំនុំជម្រះបានផ្តល់ឱកាស ដល់អ្នកទាំងនោះដើម្បីសួរដេញដោល និងតទល់ជាមួយសាក្សី និងភស្តុតាងផ្សេងៗពីសំណុំរឿង ០០២[17]។

## ៣. សំអាងហេតុ

៨. ថ្វីបើមានការព្យាយាមដើម្បីចាត់ទុកថា ការលាលែងពីតំណែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង KASPER-ANSERMET ពីកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ជាកាលៈទេសៈថ្មីមួយដែលស័ក្តិសមទទួលបានការអន្តរាគមន៍របស់អង្គជំនុំជម្រះ ក្នុងការជំនុំជម្រះលើសំណុំរឿង ០០២ ក៏ដោយ ក៏អង្គជំនុំជម្រះកត់សម្គាល់ឃើញថាតាមការពិតសំណើសុំរបស់ នួន ជា នេះគឺជាសំណើសុំច្រំដែលត្រួតគ្នាស្ទើរតែទាំងស្រុងជាមួយសំណើមុនៗដែល នួន ជា ធ្លាប់បានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងដែលត្រូវបានអង្គជំនុំជម្រះសាលាដំបូង និង

---

[15] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៥ ("ប្រសិនបើជនជាប់ចោទពិតជាជឿថាព័ត៌មានដែលសាក្សីទាំងនេះបានផ្តល់ គឺជាភស្តុតាងដោះបន្ទុក និងចាំបាច់សម្រាប់ការការពារខ្លួនរបស់គាត់ គាត់នឹងដកការជំទាស់ទៅនឹងចម្លើយទាំងនេះ និងឯកភាពទទួលយកឯកសារទាំងនេះ")។

[16] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៧-៨ (ដែលបានលើកឡើងអំពីការកាត់បន្ថយដោយអង្គជំនុំជម្រះសាលាដំបូងនូវទោសរបស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ តបទៅនឹងការឃុំខ្លួនដោយខុសច្បាប់ពីសំណាក់តុលាការយោធាកម្ពុជាក្នុងសំណុំរឿង០០១ សេចក្តីសម្រេចរបស់ខ្លួនដែលបានប្រកាសថាការអូសបន្លាយពេលរបស់អង្គបុរេជំនុំជម្រះ ក្នុងការចេញសំអាងហេតុសម្រាប់ការបន្តឃុំខ្លួនជនជាប់ចោទទាំងអស់ក្នុងសំណុំរឿង០០២ បានបណ្តាលឲ្យមានការរំលោភសិទ្ធិរបស់ជនជាប់ចោទ (ដែលជនជាប់ចោទអាចស្នើសុំសំណងជួសជុលនៅពេលក្រោយ) និងការសម្រេចជាឯកច្ឆន្ទរបស់អង្គជំនុំជម្រះសាលាដំបូងដែលថាជនជាប់ចោទ អៀង ធីរិទ្ធ ពុំមានសមត្ថភាពគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ ហើយកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់ គួរត្រូវបានផ្អាក)។

[17] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១០-១៦។

00864698

E189/3

អង្គជំនុំជម្រះតុលាការកំពូលបដិសេធចោល[18]។ សំណើសុំនាពេលបច្ចុប្បន្នត្រូវបានដាក់ជូនជាថ្មី បើអង្គជំនុំជម្រះធ្លាប់បានបញ្ជាក់ម្តងហើយម្តងទៀតថាការដាក់ឯកសារច្រំដែល គឺផ្ទុយទៅនឹងសេចក្តីណែនាំមុនៗរបស់អង្គជំនុំជម្រះ និងអាចប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយឆាប់រហ័ស។

## ៣.១. សំណើសុំឲ្យមានវិធានការ

៩. អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានគូសបញ្ជាក់អំពីលក្ខខណ្ឌអតិបរមា ដែលត្រូវបានបង្កើតឡើងដោយយុត្តិសាស្ត្រអន្តរជាតិ ដែលត្រូវតែបំពេញដើម្បីទទួលបានការអនុញ្ញាតឲ្យមានការផ្អាកកិច្ចដំណើរការនីតិវិធី។ អង្គជំនុំជម្រះក៏បានកត់សម្គាល់ឃើញទៀតថា សំណើនេះពុំមានលក្ខណៈសមស្របទេ ប្រសិនបើជនជាប់ចោទពុំបានចង្អុលបង្ហាញអំពីផលប៉ះពាល់ជាក់ស្តែងណាមួយអំពីការចោទប្រកាន់លើការជំនុំជម្រះដែលកំពុងប្រព្រឹត្តទៅ ឬពុំបានបង្ហាញថា ជាសំណើដាច់ខាតនៃការផ្អាកកិច្ចដំណើរការនីតិវិធីនឹងជាមធ្យោបាយតែមួយគត់របស់អង្គជំនុំជម្រះដើម្បីចាត់វិធានការទៅលើការរំលោភណាមួយដែលត្រូវបានគេជឿថាមានទៅលើសិទ្ធិរបស់ជនជាប់ចោទនោះឡើយ[19]។

១០. អង្គជំនុំជម្រះក៏បានបដិសេធសំណើមុនៗជាច្រើនស្រដៀងគ្នានេះរបស់មេធាវីការពារក្តី នួន ជា ដែលស្នើសុំឲ្យមានកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដោយហេតុថាមេធាវីការពារក្តីពុំបានចង្អុលបង្ហាញអំពីផលប៉ះពាល់ជាក់ស្តែងណាមួយដែលបានចោទប្រកាន់ទៅលើភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០២ ដែលជាសេចក្តីសម្រេចដែលបានទទួលការឯកភាពពីសំណាក់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសេចក្តីសម្រេចលើ

---

[18] *សូមមើល ឧទាហរណ៍* សំណើសុំផ្អាកការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តី, ឯកសារ E131/2, ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១, បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ឯកសារ E116/1/1, ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១, សំណើសុំឲ្យមានវិធានជាបន្ទាន់ប្រឆាំងនឹងនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយអនុលោមតាមវិធាន ៣៥, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១២, កថាខណ្ឌ ២, ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើរបស់ នួន ជា ស្នើសុំផ្អាកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ជាបណ្តោះអាសន្ន, ឯកសារ E131/2, ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១២ និង សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ឯកសារ E116/1/7, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២ (សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើបណ្តឹងសាទុក្ខភ្លាមៗ)។

[19] សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ឯកសារ E116, ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១១ ("សេចក្តីសម្រេចលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ"), កថាខណ្ឌ ១៨, *សូមមើលផងដែរ* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឲ្យចាត់ការជាបន្ទាន់តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង, ឯកសារ E176/2/1/4, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២, កថាខណ្ឌ ៦៦ (*ដែលបានធ្វើការកត់សម្គាល់ថា* ការផ្អាកកិច្ចដំណើរការនីតិវិធីគឺជា "សំណងដែលសមស្របបំផុតចំពោះការរំលោភគោលការណ៍សច្ចធារណ៍និរទោស" និងត្រូវបានយកមកអនុវត្តជាពិសេសតែក្នុងករណីនៃការវិនិច្ឆ័យដែលមានគុណៈវិនិច្ឆ័យតែប៉ុណ្ណោះ)។

បណ្តឹងសាទុក្ខ[20]។ ស្របៀងគ្នានេះដែរ សំណើរបស់ នួន ជា នាពេលបច្ចុប្បន្នខកខានពុំបានបញ្ជាក់ច្បាស់លាស់ ឬបង្ហាញភស្តុតាងអំពីផលប៉ះពាល់ទៅលើការជំនុំជម្រះដែលកំពុងប្រព្រឹត្តទៅក្នុងសំណុំរឿង ០០២/០១ ដោយសារការលាឈប់របស់ចៅក្រម KASPER-ANSERMET ពីកិច្ចស៊ើបសួរតាមផ្លូវតុលាការលើសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ឡើយ[21]។

១១. ទាក់ទងនឹងសាក្សីដែលមេធាវីការពារក្តី នួន ជា បានស្នើសុំស្តាប់សក្ខីកម្ម និងដែលបានលើកឡើងក្នុងសំណើរបស់ នួន ជា នេះ អង្គជំនុំជម្រះអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីសម្រេចថាតើ បុគ្គលណាខ្លះក្នុងចំណោមបុគ្គលចំនួន ១០៥៤ រូប ដែលភាគីទាំងអស់បានស្នើសុំនឹងត្រូវយកមកស្តាប់សក្ខីកម្ម។ អង្គជំនុំជម្រះធ្លាប់បានគូសបញ្ជាក់អំពីតម្រូវការដើម្បីថ្លឹងថ្លែងរវាងសិទ្ធិរបស់ភាគីទាំងអស់ក្នុងការស្តាប់សក្ខីកម្មរបស់បុគ្គលនានា ជាមួយនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស[22]។

១២. កាលពីថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះក៏បានកត់សម្គាល់ឃើញទៀតថា "ការជំនុំជម្រះក្តីមួយប្រកបដោយភាពយុត្តិធម៌ និងជាសាធារណៈ ដែលជនជាប់ចោទមានឱកាសដើម្បីបង្ហាញភស្តុតាងជាឯកសារ ឬភស្តុតាងផ្សេងៗ ដែលចាំបាច់ដើម្បីបញ្ជាក់ការពិត ការសួរសំណួរទៅសាក្សីរបស់ភាគីម្ខាងទៀត និងការតតាំងជាមួយភស្តុតាងនានា ព្រមទាំងការចោទប្រកាន់នានា

---

[20] សេចក្តីសម្រេចអំពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, កថាខណ្ឌ ២១, សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើបណ្តឹងសាទុក្ខភ្លាមៗ, កថាខណ្ឌ ៣៣។

[21] ទស្សនៈរបស់អង្គជំនុំជម្រះសាលាដំបូង ពុំត្រូវបានកែប្រែដោយសេចក្តីប្រកាសព័ត៌មានរបស់ចៅក្រម Kasper-Ansermet ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១២ ឡើយ។ សេចក្តីប្រកាសនេះបានគូសបញ្ជាក់ថាមន្ត្រីបុគ្គលិកមួយចំនួននៅ អ.វ.ត.ក បានជ្រៀតជ្រែកចូលកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៤។ សេចក្តីប្រកាសនេះកំពុំបានធ្វើការលើកឡើងណាមួយអំពីការជ្រៀតជ្រែកដែលអាចកើតមានក្នុងកិច្ចស៊ើបសួរលើសំណុំរឿង ០០២ ឡើយ។

[22] *សូមមើល ឧទាហរណ៍* ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ, ឯកសារ E218, ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២, កថាខណ្ឌ ១២ (ដោយផ្តោតទៅលើការដាក់ឯកសាររបស់ នួន ជា ពាក់ព័ន្ធនឹងសាក្សីរបស់មេធាវីការពារក្តី និងការស្នើសុំឱ្យមេធាវីការពារក្តី នួន ជា (និងក្រុមមេធាវីការពារក្តីផ្សេងៗ) គូសបញ្ជាក់ត្រួសៗថាតើសាក្សីណាខ្លះត្រូវបានចាត់ទុកជាសាក្សីសំខាន់ដើម្បីបដិសេធការចោទប្រកាន់ទៅលើជនជាប់ចោទ)។ *សូមមើលផងដែរ* បុគ្គលនានាដែលភាគីស្នើសុំមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ (ដែលត្រូវបានធ្វើទៅមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ក្នុងអំឡុងពេល ឬភ្លាមៗបន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការ) ឯកសារ E236, ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ (ដែលបានរាយនាមបុគ្គលនានាដែលភាគីចាត់ទុកជាបុគ្គលចាំបាច់ដើម្បីស្តាប់សក្ខីកម្ម បន្ថែមពីលើបុគ្គលទាំងឡាយដែលមាននៅក្នុងបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី បណ្តោះអាសន្នរបស់អង្គជំនុំជម្រះ ដែលត្រូវស្តាប់សក្ខីកម្មនៅសវនាការ (ឯកសារ E131.1/1))។ ការសម្រេចជាស្ថាពរថាតើអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មរបស់សាក្សីបន្ថែមណាខ្លះក្នុងចំណោមសាក្សីទាំងអស់នេះនៅសវនាការ ប្រសិនបើមាន នៅតែកំពុងស្ថិតក្រោមការពិចារណា និងការពិនិត្យមើលឡើងវិញរបស់អង្គជំនុំជម្រះ នៅពេលដែលសវនាការលើសំណុំរឿង ០០២/០១ ចាប់ផ្តើមបន្តដំណើរការ។

មកលើជនជាប់ចោទនោះ [...] គឺជា [...] ការកែតម្រូវវិការៈទាំងឡាយណាដែលត្រូវបានចោទប្រកាន់ នៅក្នុងកិច្ចស៊ើបសួរតាមផ្លូវតុលាការមកទល់នឹងពេលបច្ចុប្បន្ន”[23]។ ការសម្រេចនេះបានទទួលការគាំទ្រពីសំណាក់អង្គជំនុំជម្រះតុលាការកំពូល ដូចដែលបានលើកឡើងខាងក្រោមនេះ៖

> បញ្ហាដែលនៅពាក់ព័ន្ធនឹងសិទ្ធិរបស់ជនជាប់ចោទ គឺទាក់ទងនឹងលទ្ធភាពនៃការបង្ហាញវត្តមានរបស់សាក្សីមួយចំនួនរបស់មេធាវីការពារក្តី ដែលសាក្សីទាំងនោះពុំត្រូវបានស្តាប់ចម្លើយក្នុងដំណាក់កាលស៊ើបសួរ។ បញ្ហានេះគឺត្រូវសម្រេចក្នុងអំឡុងពេលនៃការជំនុំជម្រះលើសំណុំរឿង០០២ ដែលកំពុងប្រព្រឹត្តទៅ ដោយនៅមានជម្រើសជាច្រើនដើម្បីដោះស្រាយការព្រួយបារម្ភដែលថាភស្តុតាងដោះបន្ទុកអាចនឹងត្រូវបានរារាំងដោយពុំត្រឹមត្រូវក្នុងការលើកឡើងក្នុងសវនាការ។ ជាក់ស្តែង ចំណុចនេះអាស្រ័យថាតើមេធាវីការពារក្តីនៅតែបន្តធ្វើសំណើសុំពិនិត្យភស្តុតាង ហើយថាតើសំណើសុំទាំងនេះអាចឱ្យទទួលយកបានក្រោមវិធាន ៨៧ ដែរ ឬយ៉ាងណា ហើយថាតើអង្គហេតុនៃសក្ខីកម្មដែលត្រូវបានស្នើសុំនោះត្រូវបានជំទាស់ដែរ ឬទេ ថាតើសាក្សីដែលត្រូវបានកោះហៅ បង្ហាញខ្លួនដែរ ឬទេ ហើយប្រសិនបើពួកគាត់ពុំបានបង្ហាញខ្លួន ថាតើអង្គហេតុនៃការស្តាប់សក្ខីកម្មទាំង ប៉ុន្មានដែលសាក្សីត្រូវបានកោះហៅឱ្យផ្តល់សក្ខីកម្មនេះអាចនឹងត្រូវបានបញ្ជាក់អះអាងដែរ ឬទេ[24] ។

១៣. នាពេលកន្លងទៅថ្មីៗនេះ ច្បាប់ដែលបានយកមកអនុវត្តលើសំណើសុំដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង បានក្លាយជាកម្មវត្ថុនៃបណ្តឹងសាទុក្ខដាច់ដោយឡែកមួយដែលស្ថិតក្រោមការពិចារណាជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងសេចក្តីថ្លែងការណ៍ជាសាធារណៈដែលត្រូវបានចោទប្រកាន់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលមេធាវីការពារក្តី នួន ជា បានដាក់កាលពីថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២[25]។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលពាក់ព័ន្ធច្រើនជាមួយបទដ្ឋាននៃការបង្ហាញភស្តុតាងដើម្បីសម្រេចថា តើការជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ អាចត្រូវបានចាត់ទុកថាបានកើតឡើងដែរ ឬយ៉ាងណា ហើយសេចក្តីសម្រេចនេះក៏ពុំឆ្លុះបញ្ចាំងអំពីសិទ្ធិអំណាចរបស់អង្គជំនុំជម្រះក្នុងការបង្គាប់ឱ្យមានកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥(២) នៃវិធានផ្ទៃក្នុងឡើយ។ ថ្វីបើដូច្នេះ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ អង្គជំនុំជម្រះតុលាការ

---

[23] សេចក្តីសម្រេចលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, កថាខណ្ឌ ១៩។

[24] សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើបណ្តឹងសាទុក្ខភ្លាមៗ, កថាខណ្ឌ ៣២។

[25] បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើសំណើសុំឱ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹងនាយករដ្ឋមន្ត្រី ហ៊ុន សែន អនុលោមតាមវិធាន ៣៥, ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២, ឯកសារ E176/2/1/1។

កិច្ចលបានកត់សម្គាល់ឃើញថាទាក់ទងនឹងដំណោះស្រាយនីតិវិធីដែលមានក្រោមវិធាន ៣៥(២) ថា "ដោយសារពេលវេលា និងធនធានមានកំណត់... ចៅក្រម ឬអង្គជំនុំជម្រះ [នៃ អ.វ.ត.ក] អាចសម្រេចមិនស៊ើបអង្កេត និង/ឬ ដាក់ទណ្ឌកម្មសម្រាប់ផលប្រយោជន៍នៃប្រសិទ្ធភាព"[26]។

១៤. ដោយសារតែសំណើសុំឲ្យផ្អាកកិច្ចដំណើរការនីតិវិធី នាពេលនេះ និងសំណើសុំឲ្យបើកកិច្ចស៊ើបសួរជាទូទៅអំពី ការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងសំណុំរឿង ០០២ មិនមានមូលដ្ឋានច្បាស់លាស់ ឬពុំទាក់ទងនឹងការជំនុំជម្រះដែលកំពុងប្រព្រឹត្តទៅនេះ នោះ ហេតុដូច្នេះ អង្គជំនុំជម្រះបដិសេធសំណើដែលលោកមេធាវីអន្តរជាតិរបស់ នួន ជា បានស្នើសុំ ។

## ៣.២ ឧទ្ទេសរបស់សមាជិកអន្តរជាតិនៃក្រុមមេធាវីការពារក្តី នួន ជា

១៥. ក្នុងការលើកឡើងចំពោះចៅក្រមជាតិនៃអង្គជំនុំជម្រះសាលាដំបូង សមាជិកអន្តរជាតិនៃក្រុមមេធាវីការពារក្តី នួន ជា បានអះអាងថា "ឥទ្ធិពលរបស់រដ្ឋាភិបាលកម្ពុជានៅក្នុងតុលាការនេះបានប៉ះពាល់ដល់*បុគ្គលិកជាតិគ្រប់រូប* និងប៉ះពាល់ដល់រឿងក្តីដែលមិនទាន់យកមកជំនុំជម្រះ*ទាំងអស់*" និងថា "ភាពអសមត្ថភាពរបស់មន្ត្រីកម្ពុជានៅ អ.វ.ត.ក (ទោះបីមានគោលការណ៍ត្រឹមត្រូវ និង/ឬ សុឆន្ទៈ) ក្នុងការអនុវត្តការងារប្រកបដោយឯករាជ្យ និងប្រកបដោយវិជ្ជាជីវៈ គឺមិនអាចប្រកែកបានឡើយ"[27]។ មេធាវីអន្តរជាតិក៏បានចោទប្រកាន់ផងដែរអំពី "ភាពគ្មានប្រយោជន៍នៃការអំពាវនាវរបស់ខ្លួនដល់ចៅក្រមកម្ពុជា" និងអះអាងថា "មន្ត្រីកម្ពុជានឹងមិនជំទាស់ទៅនឹងទស្សនៈដែលបានលើកឡើងរួចមកហើយរបស់រដ្ឋាភិបាលកម្ពុជានោះទេ"[28]។ មេធាវីបានលើកឡើងបន្ថែមទៀតថា វា "នឹងក្លាយជាភាពឆោតល្ងង់ ងងឹតងងល់ដោយចេតនា ឬអាចធ្ងន់ធ្ងរជាងនេះទៀតផងក៏ថាបាន" ប្រសិនបើទាំងចៅក្រម CARTWRIGHT និង ចៅក្រម LAVERGNE "ជឿជាក់ដោយស្មោះត្រង់ថាសហសេវិកដែលជាចៅក្រមកម្ពុជារបស់ពួកគាត់អាចចេញសេចក្តីសម្រេចដែលផ្ទុយពីការសម្រេចដែលមិនអាចប្រកែកបានរបស់រដ្ឋាភិបាលកម្ពុជា"[29] នោះ។

១៦. សមាជិកអន្តរជាតិនៃក្រុមមេធាវីការពារក្តី នួន ជា មិនបានផ្តល់នូវឯកសារសំអាងសម្រាប់គាំទ្រការចោទប្រកាន់របស់ខ្លួនអំពីសេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះសាលាដំបូង ឬផ្នែកណាមួយនៃកំណត់ហេតុសវនាការដែលអាចគាំទ្រដល់ការអះអាងដែលថា ចៅក្រមកម្ពុជានៃអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តពុំត្រឹមត្រូវ និងរំលោភលើកាតព្វកិច្ចវិជ្ជាជីវៈ និងក្រមសីលធម៌នៃភាពមិនលម្អៀងឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានព្រមានមេធាវីអន្តរជាតិការពារក្តី នួន ជា រួចហើយថាការចោទប្រកាន់មកលើចៅក្រមកម្ពុជានៃអង្គជំនុំជម្រះសាលាដំបូង ដោយសំអាងទៅលើតែ

---

[26] សេចក្តីសម្រេចរបស់ អ.ជ.ត.ក ដោយអនុលោមតាមវិធាន ៣៥, កថាខណ្ឌ ៣៩។

[27] សំណើរបស់ នួន ជា, កថាខណ្ឌ ១៩ (គូសបញ្ជាក់បន្ថែមលើអត្ថបទដើម)។

[28] សំណើរបស់ នួន ជា, កថាខណ្ឌ ២៣។

[29] សំណើរបស់ នួន ជា, កថាខណ្ឌ ១៩។

សញ្ញាតិរបស់ពួកគាត់មួយមុខ និងពុំមានអ្វីគាំទ្រតាមរយៈការយោងទៅលើកំណត់ហេតុសវនាការ គឺជាការប្រមាថមាក់ងាយ និងផ្ទុយទៅនឹងគោលការណ៍នានាដែលមានចែងក្នុងក្រមសីលធម៌ជាធរមាននៅ អ.វ.ត.ក[30]។ ហេតុដូចនេះ ការចោទប្រកាន់ធ្ងន់ធ្ងរដោយគ្មានភស្តុតាងអំពីភាពពុំត្រឹមត្រូវដោយមូលហេតុនៃការរើសអើង អាចនាំឱ្យអង្គជំនុំជម្រះប្រើប្រាស់អំណាចរបស់ខ្លួនដើម្បីដាក់ទណ្ឌកកម្មដោយអនុលោមតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង[31]។

**តាមសំអាងហេតុដូចដែលបានបញ្ជាក់ខាងលើ អង្គជំនុំជម្រះសាលាដំបូង៖**

**បដិសេធ** រាល់សំណើសុំឱ្យមានវិធានការទាំងអស់ដែលមាន នៅក្នុងសំណើសុំរបស់ នួន ជា។

**ព្រមាន** មេធាវីអន្តរជាតិការពារក្តី នួន ជា ថា កំហុសឆ្គងទៅថ្ងៃខាងមុខរបស់មេធាវីអន្តរជាតិការពារក្តី នួន ជា ដូចជាការដាក់សារណាច្រំដែល ឬការចោទប្រកាន់ពុំមានភស្តុតាងដែលមានចរិតជាការរើសអើងមកលើសមាជិកនៃអង្គជំនុំជម្រះសាលាដំបូង អាចជាមូលដ្ឋាននៃការដាក់ទណ្ឌកម្មដោយអនុលោមតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង។

ភ្នំពេញ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C

និល ណុន

[30] *ប្រៀបធៀប* ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មេធាវីនៃតុលាការ ICCl, សេចក្តីសម្រេចលេខ ECC-ASP/4/Res.1 ("ក្រមសីលធម៌នៃតុលាការ ICC", មាត្រា ៩(១) ("មេធាវីមិនត្រូវពាក់ព័ន្ធនឹងទង្វើបែបរើសអើងណាមួយទេ ក្នុងការទាក់ទងជាមួយអ្នកដទៃ [...] ដោយផ្អែកលើពូជសាសន៍ ពណ៌សម្បុរ ឬជាតិកំណើត សញ្ជាតិ [...]")។

[31] *សូមមើល* វិធាន ៣៨ នៃវិធានផ្ទៃក្នុង (ដែលផ្តល់សិទ្ធិអំណាចដល់អង្គជំនុំជម្រះ បន្ទាប់ពីបានព្រមានហើយ គឺអាចដាក់ទណ្ឌប្រឆាំងនឹងមេធាវីណាម្នាក់បាន ប្រសិនបើទង្វើរបស់មេធាវីរូបនោះបានរំលោភបំពាន ធ្វើឱ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធី ដោយរំលោភដល់ដំណើរការងារ ឬផ្ទុយនឹងមាត្រា ២១(៣) នៃកិច្ចព្រមព្រៀង)។ មាត្រា ២១(៣) នៃកិច្ចព្រមព្រៀងតម្រូវថា មេធាវីកម្ពុជា និងមេធាវីអន្តរជាតិត្រូវបំពេញមុខងារអនុលោមទៅតាមច្បាប់កម្ពុជាស្តីពីគណៈមេធាវីដូចគ្នា ដែលបានចែងថា "មេធាវីត្រូវសម្តែងជូនចៅក្រមក្នុងភាពឯករាជ និងភាពថ្លៃថ្នូរ នូវការគោរពទៅតាមមុខងារ"។ *សូមមើលផងដែរ* ក្រមសីលធម៌នៃមេធាវីដែលបានចុះក្នុងបញ្ជីគណៈមេធាវីព្រះរាជាណាចក្រកម្ពុជា, មាត្រា ២៤ (បកប្រែក្រៅផ្លូវការជាភាសាអង់គ្លេស)។ ចំណុចនេះស្របទៅនឹងក្រមសីលធម៌មេធាវីអន្តរជាតិដែរ៖ *សូមមើលឧទាហរណ៍* ក្រមសីលធម៌មេធាវីនៃតុលាការ ICC, មាត្រា ៧(១) ("មេធាវីត្រូវគោរព និងសុភាពរាបសារក្នុងការទាក់ទងជាមួយអង្គជំនុំជម្រះ [...]"; ក្រមសីលធម៌វិជ្ជាជីវៈមេធាវីការពារក្តីនៃតុលាការ ICTR, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១០, មាត្រា ១៧(១) ("មេធាវីត្រូវបំពេញការងារដោយសមរម្យ ស្មោះត្រង់ និងសុភាពរាបសារ ចំពោះមនុស្សគ្រប់រូប ដែលខ្លួនត្រូវមានទំនាក់ទំនងវិជ្ជាជីវៈជាមួយ រួមមានមេធាវី កូនក្តីរបស់ខ្លួន ចៅក្រម សមាជិកនៃការិយាល័យរដ្ឋអាជ្ញា និងមន្ត្រីរដ្ឋបាល")។